# ៦.ព្រេងទាក់ទងនឹងទំនៀមក្រោយពីសំពះផ្ទឹម ឲ្យកូនប្រុសតោងជាយស្បៃកូនស្រីចូលក្នុងបន្ទប់

---

កាលពុទ្ធសករាជកន្លងទៅបាន ៦១០ ឬ ៦២០ កាលនោះ កោះគោកធ្លក មានផែនដីដុះឡើងធំទូលាយ ហើយ មានស្ដេចចាមមកតាំងទីកន្លែងជាដំបូងនៅលើកោះនោះ ។ យូរបន្តិចមក មានស្ដេចមួយអង្គទៀត ឈ្មោះព្រះថោង នៅក្នុងប្រទេស "មន" ដោយមានអធិករណ៍ ក៏យាងមកដោយសំពៅមួយ ដែលមានពួកបម្រើជាង ១០០ នាក់ មកជាមួយ ចូលមកសុំស្ដេចចាមនៅជ្រកនឹងកោះនោះឯង ។ ស្ដេចព្រះថោងនេះ កាលជាតិមុន យកកំណើតជាសត្វត្រកួត នៅក្នុងរន្ធដើមធ្លកដែលដុះកណ្ដាលកោះនោះ ។ បានជាសន្មត ហៅថា "កោះគោកធ្លក" សមដូចមានអតីតនិទានថា ៖

សម័យនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅឯព្រះវិហារព្រះជេតពន ទ្រង់បានយាងមកប្រថាប់ក្រោមម្លប់ធ្លកម្ដង ដើម្បីធ្វើភត្តកិច្ច (ឆាន់ចង្ហាន់បិណ្ឌបាត) នៅទីនោះ ។ សត្វត្រកួត ឃើញព្រះពុទ្ធអង្គ ហេតុជាបុព្វនិស្ស័យបណ្ដាលឲ្យមានចិត្តជ្រះថ្លា ក៏ចេញមកឱនក្បាលគំនាប់ព្រះអង្គ ៣ ដង ។ ព្រះពុទ្ធអង្គ ចាប់យកបាយមួយពំនូតបោះទៅឲ្យ, សត្វត្រកួតទទួលបរិភោគឆ្អែតស្កប់ស្កល់ ហើយក៏លៀនអណ្ដាត លិទ្ធមាត់ភ្លែមៗ, ចុងអណ្ដាតសត្វនោះព្រែកជាពីរ ។ ឃើញដូច្នោះ ព្រះអង្គទ្រង់ញញឹម ។ ព្រះអានន្ទក្រាបទូលសួរភ្លាមពីទ្រង់ញញឹម ។ ព្រះអង្គទ្រង់សម្ដែងអនុបុព្វីកថា ទំនាយទឹកដីកោះនេះប្រាប់អានន្ទថា "ម្នាលអានន្ទអើយ ! អំណឹះតទៅមុខ កោះគោកធ្លកនេះ នឹងកើតទៅជានគរមួយធំមានឥទ្ធិឫទ្ធិព្រម, ឯសត្វត្រកួតក្នុងរន្ធធ្លក ដែលចេញមកឱនក្បាលនមស្ការតថាគតនេះឯងហើយ នឹងបានកើតទៅជាមនុស្ស ហើយមកសោយរាជ្យនៅនគរនេះ ជាដើមផែនដី, ឯមនុស្សក្នុងនគរនេះ និយាយមិនសូវសត្យាទេ ព្រោះម្ចាស់ផែនដី ជាតិជាសត្វមានចុងអណ្ដាតព្រែកជាពីរ" ទំនាយតែប៉ុណ្ណេះទ្រង់ក៏ស្ងៀមទៅ ។

លុះសត្វត្រកួតអស់ជីវិត ក៏ទៅកើតក្នុងត្រកូលស្ដេច "មន" គឺតួស្ដេចព្រះថោង ដែលមកសុំស្ដេចចាមនៅនេះឯង ។ លុះនៅយូរបន្តិចទៅ កើតទាស់ទែងនឹងស្ដេចចាមពីរឿងលោភទឹកដី ចេះតែឈ្លោះប្រកែកគ្នាគ្មានឈប់ ទៅជាលែងរាប់អានគ្នា ។ ស្ដេចព្រះថោង ហេតុតែឧបនិស្ស័យត្រូវបានធ្វើជាម្ចាស់កោះ និងដោយបាននមស្ការព្រះអង្គផង ក៏មានតម្រិះប្រាជ្ញាវាងវៃ, វេលាយប់ស្ងាត់ នាំមន្ត្រីចាស់ម្នាក់ ដែលជាទំនុកទុកចិត្ត យកដុំមាសប៉ុនផ្លែខ្វិតទៅកប់ក្រោមគល់ធ្លក ជម្រៅ ៣ ហត្ថ ហើយតាក់តែងជាសាវតារ សរសេរជាក់តាំងពីជីតាទួតរបស់លោកថា "បានមកចាប់កាប់គាស់រានទឹកដីកោះនេះ តាំងពីដុះឡើង បានទាំងកប់ដុំមាសប៉ុនផ្លែខ្វិតក្រោមគល់ធ្លក ជម្រៅ ៣ ហត្ថ ទុកជាព័ស្តុតាង, ដីកោះព្រះកេរ្តិ៍នេះ ត្រូវបានជាចំណែក ចែកឲ្យស្ដេចព្រះថោងជាថៅ" ហើយយកសាវតារទៅរោលផ្សែងភ្លើងឲ្យក្រហមជាំ ល្មមគេមើលឃើញថាជារបស់ចាស់ចុះមកមែន ។

តែងសេចក្ដីដូច្នេះស្រេច ទើបព្រះថោង ប្រើសេនាទាហានឲ្យទៅបណ្ដេញស្ដេចចាម ។ ស្ដេចចាម មិនព្រមដើរចេញ ប្រុងលើកទ័ពច្បាំងគ្នា ដោយអះអាងថា ជាកេរ្ដិ៍ដំណែលរៀងៗ ខ្លួន ។ ព្រះថោង តវ៉ាថា "យើងអាងមានព័ស្ដុតាងជាកេរ្ដិ៍ដំណែលរបស់យើង បានជាហ៊ានបណ្ដេញអ្នកឯង" ។ ស្ដេចចាមថា "អ្នកមានព័ស្ដុតាងយ៉ាងណា ?" ។ ព្រះថោងថា "យើងអាងសារតារពីជីតាយើងចែកដីកោះនេះឲ្យ លោកបានទាំងកប់ដុំមាសប៉ុនផ្លែខ្វិត ក្រោមគល់ធ្លក ជម្រៅ ៣ ហត្ថ ជាព័ស្ដុតាងទុកឲ្យយើង ៗ មិនទាន់ទាំងបានទៅគាស់មាសនោះផង, បើមិនជឿត្រូវតាំងភ្នាល់គ្នាយកឈ្នះចាញ់ ត្រង់បន្ទាល់នេះចុះ" ។ ស្ដេចចាម ជាមនុស្សឆោត ព្រមចុះសន្យានឹងព្រះថោង ទទួលឈ្នះចាញ់ត្រង់មានព័ស្ដុតាងក្នុងសារតារពីរខៈ គឺ ១- ត្រង់ថាជីតាចែកឲ្យ, ២- មានកប់ដុំមាសនៅគល់ធ្លក, ថាបើពិតជាមាន សុខចិត្តដើរចេញពីទីនេះ ទើបទ្រង់កំហែងទាសារតារពីព្រះថោងមើល ។ ព្រះថោងយកសារតារមកឲ្យមើល រួចសង្ហើញឲ្យជីកដីក្រោមគល់ធ្លករកដុំមាសទៀត ។ លុះឃើញពិតទាំងពីរខ ស្ដេចចាម ទាល់ប្រាជ្ញា តែក្រាញមិនព្រមដើរចេញ ក៏រករឿងនឹងលើកទ័ពមកប្រឆាំង ។ ព្រះថោង ដឹងរឿងដូច្នោះ ក៏លើកទ័ពទៅសង្គ្រុបមុន មិនឲ្យដឹងខ្លួន ចាប់បានទាំងស្ដេចចាម និងសេនាទាហាន ។ ស្ដេចចាម អង្វរសុំជីវិត សុខចិត្តថ្វាយទឹកដី និងសេនាទាហាន ។ ព្រះថោង ក៏លែងទោស ហើយដេញឲ្យទៅនៅភ្នំក្រោម ។ ស្ដេចចាម ឈឺចិត្តចុកឈាមស្លាប់ទៅ ។ ពួកបណ្ដារាស្ដ្រចាមប្រុសស្រីប៉ុន្មានព្រះថោង ក៏រឹបដាក់បន្ថោកសាសន៍ដាក់ជាជាតិ កួយ ព័រ អស់ទៅ ។

ក្រោយនោះ ព្រះថោងមានសេចក្ដីអផ្សុក បបួលសេនាទាហានទៅលេងផ្នូកខ្សាច់ដុះថ្មី ដែលមានដីមួយខណ្ឌ ទឹកមួយខណ្ឌ, ត្រូវនឹងពេលនោះទឹកនាចផង ក៏ជិះសេះទៅមើលគ្រប់កន្លែងដីដុះ លុះកំពុងតែក្រសាលសប្បាយ ស្រាប់តែទឹកជោរជន់មក លិចអស់ នៅសល់តែត្រង់កោះ ។ ហើយមិនព្រមនាចទៅវិញ, ទ្រង់ក៏ផ្ទំលេងនៅនាកោះនោះ ចាំទម្រាំទឹកនាច ។ ព្រះអាទិត្យ អស្ដង្គតទៅ, ព្រះចន្ទពេញវង់ ក៏រះឡើងភ្លឺត្រចះត្រចង់ ព្រោះវេលានោះ ជាថ្ងៃពេញបូណ៌មីខែពិសាខ ។

ថ្លែងពីនាងទាវដ្ដី1 ជាបុត្រីក្រមុំស្ដេចភុជង្គនាគ នៅនគរបាតាល មានសេចក្ដីអផ្សុក នឹងទប់ទល់តម្កល់អាត្មានៅក្នុងប្រាសាទពុំបាន ក៏ចូលទៅក្រាបបង្គំលាបិតាសុំឡើងមកលេងកម្សាន្តនៅកោះគោកធ្លក ។ បិតាក៏បើកឲ្យតាមប្រាថ្នា ។

លុះពេលអធ្រាត្រស្ងាត់ នាងក៏នាំពួកស្រីបម្រើជាង ១០០ នាក់ ជ្រែកផែនប្រឹថពីឡើងមកស្ថានមនុស្សលោកមួយរំពេច នាំគ្នាលេងទឹកននៀលននះ តាមល្បែងភេទជានាគ ពីកន្លែងមួយទៅកន្លែងមួយ នៅសល់តែកោះធំជាងគេមួយឆ្ងាយ នៅក្នុងបាងសមុទ្រ, នាងក៏នាំបរិវារទៅមើលទៀត ឲ្យបានគ្រប់ទីកន្លែង ។

ហេតុតែកុសលរបស់នាងសាងពីអតីតជាតិមក ឲ្យជាគូនឹងស្ដេចព្រះថោង ក៏បណ្ដាលឲ្យសេនាទាហានដេកលក់អស់គ្មានសល់ម្នាក់ នៅតែស្ដេចព្រះថោង ដែលចេះតែរសាប់រសល់ផ្ទំមិនលក់ ។

លុះនាងទៅដល់កោះនោះ ឃើញមនុស្សដេកលក់ត្រៀបត្រា នាងក៏មានសេចក្ដីតក់ស្លុត នឹកថា "ខ្មោចព្រាយមាយា ធ្វើឲ្យសម្បើមលងលេង ឬមួយជាមនុស្សលោកទេ ?" នឹកហើយ នាងលើកដៃបួងសួងនឹករលឹកគុណទេពតា សូមជួយឲ្យឃើញស័ក្ដិសិទ្ធទាន់ភ្នែក, បើជាខ្មោចបិសាច សូមឲ្យរលាយបាត់ទៅ, បើជាមនុស្សលោកមែនៗ ឲ្យនៅដូចដើម ។ បួងសួងគ្រប់ ៣ ដងស្រេចឃើញនៅជារូបមនុស្សដដែល នាងក៏ប្រាប់ស្រីបរិវារជាង ១០០ នាក់ ឲ្យនិម្មិតខ្លួនជាមនុស្សទាំងអស់ ព្រមទាំងខ្លួននាងផង ហើយឲ្យមានកាន់

គ្រឿងប្រដាប់គ្រប់ដៃ ជាអ្នកអញ្ជើញគ្រឿងហែនាងទៅលេងតាមរបៀបស្ដេច ។ គំនិតនាងគិតឃើញថា បើពួកមនុស្សឃើញនាង, គេដឹង គេនឹងមិនមើលងាយនាងឡើយ ព្រោះគ្មាននាងសុទ្ធតែស្រីៗ បើគេឃើញជាក្សត្រីដូច្នេះ ទើបគេខ្លាច ។

ព្រះថោងឮមាត់មនុស្សខ្សឹបគ្នារសឹបរសាវ ច្បាស់ខ្លះ មិនច្បាស់ខ្លះ ទ្រង់តើនឡើង ឈ្មៀងព្រះនេត្រាទៅឃើញសុទ្ធតែហ្វូងស្រីខ្មៅខ្មៀរខ្វារគួរអស្ចារ្យ ទ្រង់ទតឃើញច្បាស់ដោយពន្លឺព្រះចន្ទ ទ្រង់ភិតភ័យបន្តិច អរបន្តិចលាន់ព្រះឱស្ឋថា "ឃី ! និម្មិតនេះជាអ្វី ? ជាខ្មោចបិសាច អារក្ស អ្នកតាទឹក មកលេងអញ ឬមួយជាទេវតា នាគ វិជ្ជាធរ ហោះមកលេងស្ថាននេះ ? អញប្រថុយទៅសួរឲ្យដឹងដាន ព្រោះអញជាព្រះចៅផែនដីនេះ" គិតស្រេច ស្ដេចយាងចូលទៅជិត ឃើញនាងមួយមានរូបល្អឆើតពេញព្រះទ័យ សម្បុរភ្លឺវិស័យមាស មានបរិវារកាន់គ្រឿងហែហាម របៀបជាក្សត្រី ។

ស្ដេចមានព្រះបន្ទូលដណ្ដឹងសួរថា "ព្រះនាងអើយ ! កុំចាប់ទោសអូសដំណើរយើង, យើងជាស្ដេចផែនដីកោះនេះ, សូមព្រះនាងអត់ទោស ព្រះនាងជា ទេវតា នាគ វិជ្ជាធរ ឬមួយខ្មោចបិសាច រក្សាកោះនេះ ? យើងមិនដែលដឹងសោះ សូមព្រះនាងប្រាប់ កុំលាក់ !" ។ នាងទាវឌ្ដីក្រាបទូលដោយត្រង់ថា " ខ្ញុំម្ចាស់ មិនមែនទេវតា ខ្មោច បិសាច អ្វីទេ ! ខ្ញុំម្ចាស់ជាបុត្រីព្រះបាទភុជង្គនាគ មានសេចក្ដីអផ្សុក លាព្រះបិតាមកលេងកម្សាន្តនៅទីនេះ សូមទ្រង់ជ្រាប !" ។

ព្រះថោងឮដូច្នោះ ក៏មានសេចក្ដីប្រតិព័ទ្ធនឹងនាង លុងព្រះទ័យស្នើរនឹងទប់ទល់តម្កល់ព្រះកាយពុំបាន ក៏និយាយលួងលោមថា ម្ចាស់អូនអើយ ! បងមើលទៅ ហាក់ដូចជាមិនទាន់មានស្វាមីទេ" ។ នាងក៏ទូលថា "ខ្ញុំម្ចាស់នៅក្រមុំទេ" ។ ស្ដេចទ្រង់ត្រេកអរណាស់ ហើយប្រើពាក្យលួងលោមព្រះនាងថា "អូនអើយ ! បើអូនមានចិត្តអាណិតបង ៗ នឹងលើកអូនជាអគ្គមហេសីធំ ព្រោះបងគ្មានអគ្គមហេសីទេ" ។ នាងក្រាបទូលថា "បើព្រះអង្គសព្វព្រះរាជហឫទ័យនឹងខ្ញុំម្ចាស់ សូមចាំខ្ញុំម្ចាស់ត្រឡប់ទៅក្រាបទូលបង្គំព្រះវរបិតា ឲ្យទ្រង់បានជ្រាបជាមុនសិន, បើទ្រង់សព្វព្រះទ័យព្រមព្រៀងហើយ ទ្រង់នឹងហែខ្ញុំម្ចាស់មកផ្សំផ្គុំថ្វាយ, ខណៈនេះ ខ្ញុំម្ចាស់ នឹងកន្លងបវេណីមិនបានទេ ! សូមទ្រង់សណ្ដាប់ច្បាប់ស្រុកភុជង្គនាគ" ។ ព្រះថោងថា "ឱ អូនអើយ ! ជាតិប្រុស និងស្រី បើមិនទាន់បានប្រតិព័ទ្ធនឹងគ្នាទេ ហើយសន្យាដូច្នេះ, មេយអើយ ! កាលណានឹងទាបមក" ។ នាងទូលថា សូមព្រះអង្គកុំព្រួយព្រះទ័យ, នគរយើងឯនាយកាន់សច្ចៈជាប់ ហៅថា "ពាក្យសង្ឃពាក្យសត្យ", តែចាកសច្ចៈហើយ នឹងរលត់រលាយជីវិតមួយរំពេច" ។ ព្រះថោង ថា "អូនអើយ ! បងជឿហើយ តែមិនទាន់ស្រឡះចិត្ត" ។ នាងថា "បើព្រះអង្គ មិនអស់មន្ទិលក្នុងព្រះទ័យ ខ្ញុំម្ចាស់សូមថ្វាយស្លាមួយមាត់ទុកបញ្ចាំចិត្ត" ។ (ប្រហែលជាត្រង់ណេះហើយ ដែលយើងរៀបការសព្វថ្ងៃ បង្គាប់ស្រីឲ្យបៀកស្លាមួយម៉ាត់ជូនដល់ដៃប្ដីថ្មីថ្មោង នៅពេលតោងស្បៃគ្នាចូលទៅក្នុងបន្ទប់) ។ រួចនាងក៏លាព្រះថោង ទៅស្ថានភុជង្គនាគ ក្រាបទូលបិតាមាតា តាមដំណើររឿងសព្វគ្រប់ ។

ស្ដេចភុជង្គនាគយល់ព្រមតាមបុត្រី ទ្រង់ឲ្យរៀបពលសកលយោធា និងគ្រឿងបណ្ណាការ ហែកូនស្រីឡើងមកឋានមនុស្សលោក, ទ្រង់បង្គាប់សេនានាគរាជ ដែលមានឫទ្ធិទាំងប៉ុន្មាន ឲ្យជប់បង្អុះទឹកឲ្យគោកជាផែនដីធំទូលាយឡើង ហើយឲ្យនិម្មិតជាវាំងប្រាសាទ បានគ្រប់គ្រាន់ កុំឲ្យខ្វះចន្លោះអ្វី ។

ស្ដេចព្រះថោង ក៏ចូលទៅថ្វាយបង្គំបិតាមាតាក្មេក ។ ស្ដេចនាគ ទ្រង់បង្គាប់ឲ្យព្រះសុណិសារៀបខ្លួន ព្រមទាំងសេនា នឹងរៀបមង្គលការផ្សំផ្គុំអភិសេកឲ្យសោយរាជសម្បត្តិ ។ លុះរួចស្រេចមង្គលការនៅទីនោះហើយ នឹងត្រូវយាងស្ដេចទៅអភិសេកឯឋានភុជង្គនាគម្ដងទៀត ដើម្បីឲ្យប្រជារាស្ត្រស្គាល់ផង នឹងថ្វាយនាមនគរ តាមបុត្រទាំងពីរ ជាថ្មីផង ។

ព្រះថោង ឮដូច្នោះ ទ្រង់ព្រួយព្រះទ័យជាអនេក ដោយយល់ថា "ព្រះអង្គជាមនុស្ស នឹងជ្រែកដីទៅតាមបង្គាប់បិតាក្មេកដូចម្ដេចបាន ? មុខជាខ្មាសគេក្នុងគ្រានេះហើយ", ព្រះអង្គទ្រង់វិតក្កឡើងព្រះភក្ត្រក្រហមជាំខ្មៅ ។

ព្រះនាងនាគអគ្គមហេសីឃើញដូច្នោះ ក៏ទូលសួរភ្លាមថា "ហេតុអ្វី បានជាព្រះអង្គពុំសប្បាយព្រះទ័យ ហើយមិនសោយព្រះស្ងោយដូច្នេះ ? ឬក៏ព្រះអង្គអាក់អន់ព្រះទ័យនឹងខ្ញុំម្ចាស់ពីរឿងអ្វីឬ ? ឬមួយ ព្រះអង្គអាក់អន់ព្រះទ័យនឹងមន្ត្រីមនុស្ស – មន្ត្រីនាគធ្វើឲ្យខុសឆ្គង ? សូមព្រះអង្គស្វាមីមានព្រះបន្ទូលឲ្យខ្ញុំម្ចាស់ដឹងផង" ។ ព្រះថោង ដោយមានសេចក្ដីស្នេហានឹងមហេសីថ្មីថ្មោងស្មើជីវិត នឹងលាក់ពុំបាន, បើតាមសេចក្ដីខ្មាសមិនចង់ប្រាប់ទេ តែខំស្ដីកាត់ទាំងក្ដីអៀនខ្មាសថា "ហៃអូនជីវិតបង ! បងគ្មានអាក់អន់នឹងអូន ឬមន្ត្រីណាទេ ! បងព្រួយ ព្រោះព្រះវរបិតាឲ្យបងទៅរៀបអភិសេកឯឋានភុជង្គនាគទៀត អូនដឹងទេ ! ខ្លួនបងជាមនុស្ស ធ្វើម្ដេចនឹងទៅតាមអូនបាន ? ដោយហេតុដូច្នេះហើយ ទើបបានជាបងព្រួយ" ។ នាងក្រាបទូលថា "ការត្រង់នេះស្រេចនៅលើខ្ញុំម្ចាស់ កុំព្រះអង្គព្រួយ ! សុំព្រះអង្គស្ដេចសោយព្រះស្ងោយឲ្យស្កប់ស្កល់ទៅ ! ចាំដល់ពេលដែលហែចេញទៅ សូមព្រះអង្គចាប់ជាយស្បៃខ្ញុំម្ចាស់ឲ្យជាប់កុំលែង គង់នឹងទៅរួចដូចគេហើយ ឯពួកនាម៉ឺនមុខមន្ត្រី និងសេនាទាហាន ដែលហែទៅទាំងប៉ុន្មាន ត្រូវឲ្យតោងតែជាយព្រះពស្ត្រព្រះរៀមឲ្យជាប់ ក៏អាចទៅបានដល់ឋានភុជង្គនាគដូចគ្នា គ្មានបញ្ហាអ្វីឡើយ ។

ព្រះថោង ក៏មានសេចក្ដីត្រេកអរឡើងវិញ ហើយទ្រង់ប្រាប់មន្ត្រីទាំងអស់ តាមបង្គាប់អគ្គមហេសី ។ លុះដល់វេលានឹងហែទៅ ព្រះថោង ក៏តោងជាយស្បៃនាងទាវដ្ដី, ពួកនាម៉ឺនមន្ត្រី ក៏តោងព្រះពស្ត្រស្ដេចតៗគ្នា គ្រប់ទាំងប្រុសទាំងស្រី ទៅរហូតដល់ឋានភុជង្គនាគ ។

ព្រះបាទភុជង្គនាគ រៀបអភិសេកកូននៅឋានភុជង្គនាគរួច ទ្រង់ក៏ថ្វាយនាមជាថ្មីទាំងអស់ ។ ព្រះថោង ជាព្រះបាទអាទិច្ចវង្សា, នាងទាវដ្ដី ជានាងទាវធីតា, កោះគោកធ្លក ជាក្រុងកម្ពុជាធិបតី ដែលឋិតនៅក្នុងការទំនុកបម្រុងនៃនគរភុជង្គនាគ ។ ព្រះបាទភុជង្គនាគ ទ្រង់ចាត់នាគសេនាមានឫទ្ធិ ២ រូប ឲ្យមកគាល់បម្រើនិងការពារជានិច្ច បង្ការក្រែងបើមានភ័យសឹកសង្គ្រាមមកសង្កត់សង្កិន នឹងបានដឹងដំណឹងឆាប់ អាចឲ្យលើកពលសកលយោធាមកជួយការពារទាន់ ។

ត្រង់នេះហើយ ដែលគេតែងតែធ្វើតមកដល់សព្វថ្ងៃ គឺកាលណាក្រោកឡើងពីអង្គុយផ្ទឹមសំពះការ គេឲ្យកូនប្រុសតោងជាយស្បៃកូនស្រីចូលទៅក្នុងបន្ទប់ ដោយយកតម្រាប់តាមព្រះបាទអាទិច្ចវង្សា ដែលតោងស្បៃនាងនាគជាអគ្គមហេសីទៅឋានភុជង្គនាគនោះឯង ។